ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : 008/១ កសស.អល

**លទ្ធកម្ម ក.ស.ស**

## សេចក្តីជូនដំណឹង

**ស្តីពី**

**ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់អាគុយគ្រប់ប្រភេទ ផលិតនៅប្រទេសជប៉ុន-កូរ៉េ-អាល្លឺម៉ង់ សម្រាប់ឆមាសទី ២ ឆ្នាំ ២០១៨**

កំពង់ផែស្វយ័តក្រុងព្រះសីហនុសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា: កំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់អាគុយគ្រប់ប្រភេទ ផលិតនៅប្រទេសជប៉ុន-កូរ៉េ-អាល្លឺម៉ង់ សម្រាប់ឆមាសទី ២ ឆ្នាំ ២០១៨ ជូនកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ ដែលមានអាសយដ្ឋាន: កំពង់ផែស្វយ័តក្រុងព្រះសីហនុ ចាប់ពីថ្ងៃ **០២** ខែ **តុលា** ឆ្នាំ **២០១៨** តទៅ រៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទំនាក់ទំនងលេខ **012 912 034** ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង **១០:០០ ព្រឹក** ថ្ងៃទី **០២** ខែ **វិច្ឆិកា** ឆ្នាំ **២០១៨** ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ តាមអាសយដ្ឋានខាងលើ វេលាម៉ោង **១០:០០ ព្រឹក** ថ្ងៃទី **០២** ខែ **វិច្ឆិកា** ឆ្នាំ **២០១៨** ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរពត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

*ថ្ងៃ សុក្រ ៤រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២*

*ខេត្តព្រះសីហនុ,ថ្ងៃទី 28 ខែ កញ្ញា ឆ្នាំ ២០១៨*

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាប្រធានអគ្គនាយក**

**និងជា ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**លូ_គីមឈន់**

**ចម្លងជូន**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ